# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ..៧១..ស.សរ.ក.

## សេចក្តីសម្រេច

ស្តីពី

ការបំពេញបន្ថែមសមាជិកក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- យោងសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលស្តីពីការបង្កើតក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា
- យោងសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជាលេខ០១ សណន ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤ ស្តីពីតួនាទី ភារកិច្ច និងរបៀបរបបការងារសម្រាប់ក្រុមការងារចុះបំពេញបេសកកម្មតាមមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១ .-**

ត្រូវបានបំពេញបន្ថែមសមាជិកក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានដើម្បីត្រួតពិនិត្យ និងគាំទ្រការ អនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា **នៅខេត្តព្រះសីហនុ** ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. ឯកឧត្តម **ហោ សុធន** | អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ២. ឯកឧត្តម **ឡុញ ហ៊ាល** | អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេសក្រសួងបរិស្ថាន | សមាជិក |
| ៣. ឯកឧត្តម **ទ្រី សុខហេង** | អនុប្រធានក្រុមប្រឹក្សានីតិកម្ម ក្រសួងមហាផ្ទៃ | សមាជិក |
| ៤. លោកជំទាវ **សេង វណ្ណារី** | ទីប្រឹក្សាអមក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ៥. ឯកឧត្តម **ចាន់ សុធី** | អគ្គនាយក នៃអគ្គនាយកដ្ឋានថវិកា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៦. ឯកឧត្តម **ណោប សាមុត** | អគ្គនាយក នៃអគ្គនាយកដ្ឋានទេសចរណ៍ ក្រសួងទេសចរណ៍ | សមាជិក |
| ៧. ឯកឧត្តម **ចាន់ បុរិន្ទ** | ប្រធានវិទ្យាស្ថានស្តង់ដារកម្ពុជា ក្រសួងឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |
| ៨. លោក **ឈុន ពុទ្ធារិទ្ធ** | អគ្គនាយករង នៃអគ្គនាយកដ្ឋានកិច្ចការបច្ចេកទេស ក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ៩. លោក **ស៊ីន ចាន់សិរីវុត្ថា** | អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | សមាជិក |
| ១០. លោក **ណុប កនណាវុឌ្ឍ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានផែនការ ក្រសួងផែនការ | សមាជិក |
| ១១. លោក **ស៊ីសុវត្ថិ ភានុវត្ត** | អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១២. លោក **មាស ពេជ្រ** | អគ្គនាយករង នៃអគ្គនាយកដ្ឋានគ្រប់គ្រង មុខងារសាធារណៈ ក្រសួងមុខងារសាធារណៈ | សមាជិក |
| ១៣. លោកស្រី **សួរ ដានី** | អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងយុត្តិធម៌ | សមាជិក |
| ១៤. លោក **ផៃ គឹមឈាន** | អគ្គនាយករង នៃអគ្គនាយកដ្ឋានបច្ចេកទេស ក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១៥. លោក **សុន សេងហួត** | អគ្គនាយករង នៃអគ្គនាយកដ្ឋានសហគ្រាសធុនតូច និងមធ្យម ក្រសួងឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |

| | | |
|---|---|---|
| ១៦. លោក **សឿន ប៊ុនលី** | អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១៧. ឧត្តមសេនីយ៍ទោ **គង់ ប៊ុនថន** | មេបញ្ជាការរង និងជាសេនាធិការយោធភូមិភាគទី៣ | សមាជិក |
| ១៨. លោក **ជា សុជាតិ** | ប្រធាននាយកដ្ឋានកិច្ចការប្រេងកាតអន្តរជាតិ ក្រសួងរ៉ែ និងថាមពល | សមាជិក |
| ១៩. លោក **ម៉ូវ ចរិយា** | ប្រធានបញ្ញត្តិករ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |

**ប្រការ២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាមី រដ្ឋបាលខេត្តព្រះសីហនុ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មករា ឆ្នាំ២០១៤

ឧបនាយករដ្ឋមន្ត្រី

ស ខេង

<u>កន្លែងទទួល:</u>

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី*
*-គ្រប់ក្រសួង ស្ថាប័ន*
*-រដ្ឋបាលថ្នាក់ក្រោមជាតិ*
*-រាជកិច្ច*
*-ឯកសារ-កាលប្បវត្តិ*



www.pheakdeylaw.com